00293334

E23/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27/03/2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខៈ០០១/១៨ កក្កដា ឆ្នាំ ២០០៧-អវតក/អជសដ
Case File/Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| **ចំពោះមុខ** | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ | ថ្ងៃទី ២៧ មីនា ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30/03/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

## សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត
Pierre Oliver SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX

00293335

001/18-07-2007-ECCC/TC

E23/4

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Silke STUDZINSKY

Martine JACQUIN

Philippe CANNONE

ទី ស្រីនណា

Elizabeth RABESANDRATANA

Karim KHAN

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ (“សេចក្តីសម្រេច”) ។

**បានឃើញ** សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើសេចក្តីសន្និដ្ឋានក្នុងអំឡុងសវនាការលើអង្គសេចក្តី ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩[1]។

**បានទទួល** សំណើសុំបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ ទាក់ទិននឹងសិទ្ធិរបស់ពួកគាត់ក្នុងការដាក់សេចក្តីសន្និដ្ឋាននៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តីដែលបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ (“សំណើសុំ”)[2]។

**បានឃើញ** សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការកំណត់កាលបរិច្ឆេទឆ្លើយតបទៅនឹងសំណើសុំបន្ទាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២) ក្នុងការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩ (“សេចក្តីណែនាំ”)[3]។

**បានទទួល** ចម្លើយតបពីការិយាល័យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីដែលជំទាស់សំណើសុំរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីខាងលើ[4]។

**កត់សម្គាល់ឃើញថា** មិនមានភាគីណាផ្សេងទៀតបានដាក់ចម្លើយតបតាមកាលបរិច្ឆេទដែលបានកំណត់។

**ក្រោយពីបានពិចារណាលើ** សេចក្តីសន្និដ្ឋានដែលបានលើកឡើងក្នុងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ នេះដែលបានស្នើសុំអោយអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតអោយមេធាវីតំណាង

[1] មើលឯកសារ E19

[2] មើលឯកសារ E23

[3] មើលឯកសារ E23/1

[4] មើលឯកសារ E23/2 និងឯកសារ E23/3

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • E T C

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី និងក្រោយពីបានពិចារណាលើចម្លើយតបរបស់ភាគីនានានៃរឿងក្តី។

**ដោយអនុលោម** តាមវិធាន ៨៩ ស្ទួននៃវិធានផ្ទៃក្នុង។

**ចេញសេចក្តីសម្រេចដូចខាងក្រោម:-**

**អង្គហេតុ**

១. កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីណែនាំស្តីពីការធ្វើសេចក្តីសន្និដ្ឋានក្នុងពេលសវនាការលើអង្គសេចក្តី ដែលតាមរយៈសេចក្តីណែនាំនេះ មានតែសហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចំពោះការចោទប្រកាន់ ដែលភាគីនីមួយៗមានរយៈពេល ២ ម៉ោង។ តាមសេចក្តីណែនាំដែលអង្គជំនុំជម្រះបានបញ្ជាក់ថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនមានត្រូវបានអនុញ្ញាតអោយធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ឬមេធាវីការពារជនជាប់ចោទឡើយដោយមូលហេតុខ្លួនយល់ឃើញថាមាត្រា ៨៩ ស្ទួន នៃវិធានផ្ទៃក្នុងមិនបានចែងពីសិទ្ធិបែបនេះសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

២. នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ បានដាក់ជូនដល់អង្គជំនុំជម្រះសាលាដំបូងនូវសំណើបន្ទាន់មួយទាក់ទងនឹងការស្នើសុំអោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាបើទោះបីជាវិធាន ៨៩ ស្ទួន នៃវិធានផ្ទៃក្នុងមិនបានចែងផ្តល់សិទ្ធិបែបនេះក៏ដោយ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថាចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គ្មានអំណាចក្នុងការធ្វើវិធានផ្ទៃក្នុងនេះទេ ហើយម្យ៉ាងទៀតវិធាន ៨៩ ស្ទួន នៃវិធានផ្ទៃក្នុងដែលមិនអនុញ្ញាតអោយមានសិទ្ធិស្មើគ្នាក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទក្នុងដំណើរនីតិវិធីជំនុំជម្រះចំពោះមុខ អ.វ.ត.ក នោះគឺជាការផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ការមិនអនុញ្ញាតនេះគឺផ្ទុយផងដែរទៅនឹងវិធាន ២១(១) នៃវិធានផ្ទៃក្នុងដែលតម្រូវអោយមានតុល្យភាពនៃសិទ្ធិរវាងភាគីនានានៃរឿងក្តី។ សិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានគឺជាធ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានក្នុងនាមជាភាគីក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌដែលមានចែងនៅក្នុងវិធាន ២៣(៦)(ក) នៃវិធានផ្ទៃក្នុងហើយសិទ្ធិបែបនេះគឺមានការទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។ ជាចុងបញ្ចប់នោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកផងដែរថា ការមិនបានចែងពីសិទ្ធិធ្វើសេចក្តីសន្និដ្ឋានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះគឺជាកំហុសក្នុងការតាក់តែងវិធាន ឬជាការភាន់ច្រឡំមួយ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

៣. ឆ្លើយតបទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំយោបល់ពីភាគី ទាំងសហព្រះរាជអាជ្ញា ទាំងមេធាវីការពារជនជាប់ចោទបានការយល់ឃើញដូចគ្នាថាវិធាន ៨៩ ស្ទួន អនុញ្ញាតអោយតែសហព្រះរាជអាជ្ញា និងមេធាវីជនជាប់ចោទប៉ុណ្ណោះក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទ ហើយមិនមែនជាកំហុសក្នុងការតាក់តែងវិធាននោះទេ។ សហមេធាវីការពារក្ដីកត់សម្គាល់ឃើញថាវិធាននេះត្រូវបានស្នើធ្វើវិសោធនកម្មដោយគណកម្មការនីតិវិធី និងវិធានផ្ទៃក្នុងនៅពេលកិច្ចប្រជុំពេញអង្គនាខែមីនា ឆ្នាំ ២០០៩ ដែលកំរិតសិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋានសម្រាប់តែសហព្រះរាជអាជ្ញា និងមេធាវីជនជាប់ចោទតែប៉ុណ្ណោះ។ ចំណែកសហព្រះរាជអាជ្ញាបានយល់ឃើញថាសិទ្ធិមួយចំនួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ជាលក្ខណៈទូទៅនោះ មិនអាចដូចគ្នាទាំងស្រុងទៅនឹងសិទ្ធិរបស់សហព្រះរាជអាជ្ញា ឬមេធាវីការពារជនជាប់ចោទនោះទេ។

**<u>ការយល់ឃើញ</u>**

៤. អង្គជំនុំជម្រះយល់ឃើញថាបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង (វិធាន ៨៩ ស្ទួន) ក៏ដូចជាបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុ ជាជាធរមានទាក់ទងនឹងការធ្វើសេក្ដីសន្និដ្ឋានចោទប្រកាន់ គឺមិនបានអនុញ្ញាតផ្ដល់សិទ្ធិអោយដើមបណ្ដឹងរដ្ឋប្បទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ២ នៃវិធានផ្ទៃក្នុងចែងថា *"(...) អង្គជំនុំជម្រះត្រូវធ្វើការសម្រេចចិត្តដោយស្របទៅលើ មាត្រា ១២-១ នៃកិច្ចព្រមព្រៀង និងមាត្រា ២៣ ថ្មី, ៣៣ ថ្មី ឬមាត្រា ៣៧ថ្មី នៃច្បាប់ស្ដីពីការបង្កើតអង្គ ជំនុំជម្រះវិសាមញ្ញ និងដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមាន ចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និងច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន (...)"*។

<u>ចំពោះគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង៖</u>

៥. វិធាននេះគ្រាន់តែចែងថារាល់បទប្បញ្ញត្តិ ឬសេចក្ដីណែនាំអនុវត្តនៃ អ.វ.ត.ក ត្រូវតែធ្វើការបកស្រាយក្នុងន័យការពារជានិច្ចដល់ជនជាប់ចោទ និងជនរងគ្រោះក៏ដូចជាការធានាអោយបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

៦. អង្គជំនុំជម្រះមិនបដិសេធទេថាដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគីមួយនៃរឿងក្ដី ដោយអនុលោមតាម វិធាន ២៣(៦)(ក) នៃវិធានផ្ទៃក្នុង។ ប៉ុន្តែសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចដូច ឬស្មើគ្នាទាំងស្រុងទៅនឹងភាគីនានានៃរឿងក្ដីបានទេ ប្រសិនបើសិទ្ធិនោះវិធានបានកំណត់ផ្ដល់ជាក់លាក់ចំពោះតែភាគីផ្សេងក្រៅពីដើមបណ្ដឹងរដ្ឋប្បវេណីនោះ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

- <u>ចំពោះច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមាន</u>៖

៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាធរមានជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ មិនមានចែងពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការ ធ្វើសេចក្តីសន្និដ្ឋានចោទក្នុងរឿងព្រហ្មទណ្ឌនោះទេ។

- <u>ចំពោះកិច្ចព្រមព្រៀង និងច្បាប់បង្កើត អ.វ.ត.ក</u>៖

៨. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាមាត្រា ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ នៃច្បាប់បង្កើត អ.វ.ត.ក ផ្តល់អាទិភាពដល់ច្បាប់ជាតិដែលនៅជាធរមានជាចម្បង ហើយនៅពេលដែលច្បាប់ ឬនីតិវិធីទាំងនោះមានចន្លោះប្រហោងមិនមានចែងករណីពិសេស ឬមិនសមស្របជាមួយបទដ្ឋានអន្តរជាតិនោះទើបចៅក្រមអាចស្វែងរកបទដ្ឋាននីតិវិធីក្នុងកំរិតអន្តរជាតិ។

៩. វិធាន ៨៩ ស្ទួន (២) នៃវិធានផ្ទៃក្នុងចែងថា *"នៅមុនពេលសួរចម្លើយរបស់ជនជាប់ចោទ សហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន"*។ វិធាននេះមានភាពច្បាស់លាស់ហើយក៏ជាវិធានមួយដែលបានកំណត់ពីលក្ខខណ្ឌសមភាពនៃសិទ្ធិដែលមានលក្ខណៈទូទៅក្នុងវិធាន ២១ ព្រោះថាសេចក្តីសន្និដ្ឋានអនុញ្ញាតអោយដល់តែសហព្រះរាជអាជ្ញា ជនជាប់ចោទ ឬមេធាវីរបស់ខ្លួនប៉ុណ្ណោះ ហើយសេចក្តីសន្និដ្ឋានដែលធ្វើឡើងគឺត្រូវទាក់ទងនឹងការចោទប្រកាន់ជនជាប់ចោទ។ ដូច្នេះ ស្មារតីនៃវិធាន ៨៩ ស្ទួន (២) ដែលបានបង្កើតឡើងដោយគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង គឺមិនមែនសម្រាប់ជាការថ្លែងបើក ឬចំណាប់អារម្មណ៍ដែលមានលក្ខណៈទូទៅដែលភាគីនានានៃរឿងក្តីគួរត្រូវបានផ្តល់ឱកាសអោយដោយស្មើគ្នានោះទេ។

- <u>អំនះអំណាងស្តីកំហុសឆ្គងក្នុងការតាក់តែងវិធានផ្ទៃក្នុង</u>៖

១០. វិធានផ្ទៃក្នុងបានគិតទៅដល់ការធ្វើអោយមានតុល្យភាពនៃសិទ្ធិរវាងភាគីទាំងឡាយដោយបង្កប់ផងដែរនូវតួនាទីខុសៗគ្នារវាងសហព្រះរាជអាជ្ញា មេធាវីការពារក្តី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ការអះអាងថាវិធាន ៨៩ ស្ទួនគឺជាកំហុសឆ្គងមួយនៃការតាក់តែងនោះ គឺជាយល់ឃើញមួយមិនត្រឹមត្រូវ។ វិធាន ៨៩ (២) ស្ទួន នៃវិធានផ្ទៃត្រូវបានពិចារណាឡើងវិញនៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០០៩ ជាលទ្ធផលនោះគឺកិច្ចប្រជុំបានសម្រេចថាគ្មានកំហុសឆ្គងឬការធ្វេសប្រហែសក្នុងការតាក់តែងវិធាននេះដែលតម្រូវអោយអង្គជំនុំជម្រះសាលាដំបូងធ្វើការកែតម្រូវដោយអនុញ្ញាតសិទ្ធិធ្វើសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

**ដោយផ្អែកលើការយល់ឃើញខាងលើ**

អង្គជំនុំជម្រះសាលាដំបូងសម្រេច**បដិសេធ** សំណើដែលបានស្នើឡើង។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**